ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីជូនព័ត៌មានស្តីពីលទ្ធផល
# ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តម រ៉ូឌ្រីហ្គោ ឌូតឺតេ (Rodrigo Duterte)
# ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីននៅព្រះរាជាណាចក្រកម្ពុជា
# ថ្ងៃទី១៣-១៤ ខែធ្នូ ឆ្នាំ២០១៦

---------------------

តបតាមការអញ្ជើញរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម រ៉ូឌ្រីហ្គោ ឌូតឺតេ (Rodrigo Duterte) ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន បានដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ១៣ ដល់ទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦។

ឯកឧត្តម រ៉ូឌ្រីហ្គោ ឌូតឺតេ និងគណៈប្រតិភូ បានចូលក្រាបបង្គំគាល់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។

ក្នុងអំឡុងពេលការចរចារផ្លូវការដែលបានប្រព្រឹត្តទៅនៅវិមានសន្តិភាពនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១៦ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តមប្រធានាធិបតី ឌុយតឺតេ បានធ្វើការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមក និងបានពិភាក្សាលើការពង្រឹង និងធ្វើឲ្យស៊ីជម្រៅនូវទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

សម្តេចតេជោ ហ៊ុន សែន បានស្នើឯកឧត្តមប្រធានាធិបតីឌុយតឺតេ ធ្វើការពិនិត្យពីកាលានុវត្តភាពក្នុងការជម្រុញកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យពាណិជ្ជកម្ម ទេសចរណ៍ ការងារ និងការវិនិយោគលើវិស័យកសិកម្ម ជាពិសេសស្រូវ ព្រមទាំងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងការរត់ពន្ធគ្រឿងញៀន។ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានបញ្ជាក់ពីការគាំទ្រ និងការអបអរសាទររបស់កម្ពុជា ដល់ប្រទេសហ្វីលីពីនដែលនឹងធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០១៧។

ឯកឧត្តមប្រធានាធិបតី ឌូតឺតេ បានជំរុញប្រទេសទាំងពីរលើកកំពស់កិច្ចសហប្រតិបត្តិការ ជាពិសេសក្នុងផ្នែកស្រូវ ការអភិវឌ្ឍធនធានមនុស្ស ការតភ្ជាប់រវាងប្រជាជន និងប្រជាជន។ ឯកឧត្តមក៏បាន

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ជំរាបជូនសម្តេចតេជោនាយករដ្ឋមន្ត្រី ពីការសម្រេចចិត្តរបស់ឯកឧត្តមក្នុងការផ្តល់អាហារូបករណ៍ចំនួន ៦០កន្លែងដល់និស្សិតកម្ពុជាទៅសិក្សានៅហ្វីលីពីន នៅក្នុងឆ្នាំសិក្សា២០១៧។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណហ្វីលីពីនចំពោះការផ្តល់អាហារូបករណ៍ និង ជំនួយចំពោះកម្ពុជា។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានស្នើឲ្យក្រសួងការបរទេសនៃប្រទេសទាំងពីររៀបចំ រួមគ្នាពិធីរំលឹកខួបអនុស្សាវរីយ៍៦០ ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ នៅឆ្នាំ ២០១៧ និងរៀបចំកិច្ចប្រជុំលើកទី២របស់គណៈកម្មការចំរុះកិច្ចសហប្រតិបត្តិការទ្វេភាគី ដែលរដ្ឋមន្ត្រីការ បរទេសនៃប្រទេសទាំងពីរជាប្រធាន។

បន្ទាប់ពីកិច្ចចរចាផ្លូវការ សម្តេចតេជោនាយករដ្ឋមន្ត្រី និងឯកឧត្តមប្រធានាធិបតី ឌុយតឺតេ បានធ្វើ ជាសាក្សីក្នុងពិធីចុះហត្ថលេខាលើឯកសារ ដូចខាងក្រោម៖

- អនុស្សារណៈយោគយល់គ្នា រវាងនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា និងនគរបាលជាតិ នៃសាធារណរដ្ឋហ្វីលីពីន ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលត្រូវបានចុះហត្ថលេខាដោយឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម Perfector Yasay រដ្ឋមន្ត្រីការបរទេសហ្វីលីពីន

- អនុស្សារណៈនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ ដែលត្រូវបានចុះហត្ថលេខាដោយឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម Perfector Yasay រដ្ឋមន្ត្រីការ បរទេសហ្វីលីពីន

- អនុស្សារណៈនៃកិច្ចព្រមព្រៀងរវាងក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា និងគណកម្មាការកីឡានៃសាធារណរដ្ឋហ្វីលីពីន ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកីឡា ដែលត្រូវបានចុះហត្ថលេខាដោយឯកឧត្តម ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និងឯកឧត្តម Perfector Yasay រដ្ឋមន្ត្រីការបរទេសហ្វីលីពីន និង

- កម្មវិធីអនុវត្តនៃកិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ (២០១៦-២០២០) រវាងក្រសួង ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងទេសចរណ៍នៃសាធារណរដ្ឋហ្វីលីពីនដែល ត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និង លោកជំទាវ Wanda Corazon Tulfo-Teo រដ្ឋមន្ត្រីទេសចរណ៍ហ្វីលីពីន។

ភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦